# ការសំភាសន៍របស់អ៊ុំស្រី ឆូវ គឹមរុណា

កៈ អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ ឆូវ គឹមរុណា

## <u>ការសង្ខេបប្រវត្តិរបស់របស់អ៊ុំស្រី ឆូវ គឹមរុណា</u>

អ៊ុំស្រី ឆូវ គឹមរុណា មានអាយុ67ឆ្នាំហើយនៅក្នុងឆ្នាំ2018។អ៊ុំស្រី ឆូវ គឹមរុណា មានភេទស្រី។អ៊ុំស្រី ឆូវ គឹមរុណា មានទីលំនៅបច្ចុប្បន្ននៅភូមិជហុក ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ បានក្មួយបានអត់អីទេ

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី18 ខែ2ឆ្នាំ2018 ហើយការសំភាសន៍មួយនវត្រូវបានសំភាសន៍នៅភូមិជហុក ឃុំអំពិល ស្រុកអីគេដែរអ៊ុំ?

ខៈ នៅស្រុកកំពង់សៀម

កៈ ស្រុកកំពង់សៀម ខេត្តកំពង់ចាមអ៊ុំ ចឹងសំរាប់អ៊ុំមានឈ្មោះអីគេដែរអ៊ុំឈ្មោះពេញរបស់អ៊ុំហាសអ៊ុំ?

ខ៖ អ៊ុំឈ្មោះឆូវ គឹមរុណ

ក៖ ចុះមានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះកាលបីក្មេងនឹងមាននរណាគេហៅឈ្មោះអ៊ុំអីផ្សេងដែរទេអ៊ុំ?

ខ៖ អត់មានទេហៅតែចឹងនឹង

ក៖ ចុះអ៊ុំសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ អ៊ុំអាយុ67ឆ្នាំហើយ

ក៖ អូ៎!អ៊ុំអាយុច្រើន ចុះអ៊ុំមានចងចាំថ្ងៃខែឆ្នាំកំណើតដែរអ៊ុំកើតដែរទេអ៊ុំ?

ខ៖ កើតនៅថ្ងៃទី7 ខែ9 ឆ្នាំ1953

ក៖ ចុះឆ្នាំច័ន្ទគតិអ៊ុំមានចងចាំទេជុំលក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ ខ្ញុំឆ្នាំថោះ

ក៖ ចុះអ៊ុំកើតនៅណាដែរអ៊ុំភូមិ ឃុំហាសអ៊ុំ?

ខ៖ កើតនៅកំពង់ចាមយើងនឹង នៅភូមិទួលស្បូវ

ក៖ ភូមិទួលស្បូវ ឃុំអីគេដែរអ៊ុំ?

ខ៖ ឃុំទួលស្បូវ ស្រុកកំពង់សៀមកាលពីជំនាន់ណុងហាស ខេត្តកំពង់ចាមនឹងដែរនឹង នៅកំពង់ចាមយើងនឹងនៅក្នុងក្រុងនឹងដែរតើ

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ អ៊ុំមានបងប្អូនចំនួន7នាក់

ក៖ ចុំអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ អ៊ុំជាកូនទី6

ក៖ ចុះមានស្រីប៉ុន្មាន ហើយនឹងប្រុសប៉ុន្មានដែរទៅអ៊ុំ?

ខ៖  មានស្រី6នាក់នឹងប្រុសម្នាក់

ក៖  ចុះអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេ?

ខ៖  បងប្អូននឹងស្លាប់ជំនាន់ពលពតអស់ហើយនឹង

ក៖  អូ៎!ស្លលាប់ទាំងអស់មែន?

ខ៖  ស្លាប់អស់គ្រួសារហើយ

ក៖  ចឹងមានន័យថាឥឡូវនឹងនៅប៉ុន្មានគ្រួសារដែរទៅ?

ខ៖  នៅតែ2គ្រួសារទេនឹង

ក៖  ប៉ុន្តែអ៊ុំអាចប្រាប់ឈ្មោះពួកគាត់ទាំងអស់បានទេអ៊ុំ?

ខ៖  ប្រាប់បានទាំងអស់នឹង

ក៖  ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរទៅ?

ខ៖  បងស្រីទី1ឈ្មោះ ឆូវ ហុងលាន់ មានកូន2នាក់ណាស់

ក៖  ទីបងទី2?

ខ៖  បងស្រីទី2មានឈ្មោះឆូវ ហុងឡាង មានកូន9នាក់ , បងស្រីទី3ឈ្មោះឆូវ ហុង លីម មានកូនឈ្មោះ ឆូវ ហុងលីម មានកូន3នាក់, ទី4នឹងឈ្មោះឆូវ ហុងអេង ហើយឆូវ ហុងលាន់នឹងស្លាប់ជំនាន់ពលពត ហើយនឹង

ក៖  បាទចឹងអ៊ុំ?

ខ៖  នៅតែឈ្មោះឆូវ ហុងឡាងទេ ហើយឈ្មោះឆូវ ហុងលីម មានកូន4នាក់ស្លាប់ជំនាន់ពលពតទាំង គ្រួសារហើយនឹង ហើយឈ្មោះឆូវ ហុង អេង ស្លាប់ជំនាន់ពលពតទាំងគ្រួសារ ,នឹងឈ្មោះ ឆូវ ប៉េងស្រ៊ុន នឹងទី5ហី?

ក៖  បាទអ៊ុំទី5នឹងហើយ

ខ៖  ទី5នឹងកូន4នាក់ក៏ស្លាប់នៅជំនាន់ពលពតដែរនឹងគាត់ក៏ស្លាប់ទាំងគ្រួសារដែរនឹង បានមកអ៊ុំ នឹងឆូវ គឺមរុណា នឹងប្អូនប្រុសមួយឈ្មោះ ឆូវ ម៉េងហ៊ាង គេក៏ស្លាប់នៅជំនាន់ពលពតដែរឈ្មោះឆូវ ម៉េង ហ៊ាងនឹង

ក៖  ចឹងមានន័យថាពួកគាត់ទាំងអស់នឹងមានតែប៉ុណ្ណឹងទេណាអ៊ុំ?

ខ៖  មានតែប៉ុណ្ណឹងនាក់ទេនឹង គេភាគច្រើនស្លាប់ទាំងគ្រួសារតែម្តងនឹង

ក៖  ចឹងមានន័យថារាល់ថ្ងៃនឹងនៅតែ2នាក់ទេណាអ៊ុំ?

ខ៖  នៅតែ2នាក់បងប្អូនបង្កើតនឹង

ក៖  អ្នកនៅបងទីប៉ុន្មានដែរអ៊ុំ?

ខ៖  នៅបងទី2 ហើយនឹងអ៊ុំ

ក៖  ចុះបងទី2នឹងសព្វថ្ងៃនឹងគាត់រស់នៅណាដែរអ៊ុំ?

ខ៖  សព្វថ្ងៃនឹងគាត់រស់នៅវាលវង្សនឹងណាស់នៅកំពង់ចាមនឹងដែរនឹង នៅក្រុងកំពង់ចាមនឹងតែម្តងនឹង

ក៖  ប៉ុន្តែគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖  គាត់ចាស់ហើយអាយុប៉ែតជាងហើយនឹង

ក៖  ចុះអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់ រឺក៏មានអនុស្សាវរីយ៍លេងអីជាមួយគាត់កាលពីអ៊ុំនៅក្មេងៗ ហាសអ៊ុំ?

ខ៖  អីគ្មានទេ

ក៖ លក្ខណះលេងឡឹកបាយឡ រឺលេងថុយ?

ខ៖

នៅកាលពីក្មេងនឹងអ៊ុំនៅគិតតែពីរៀនចឹងកើតមកនឹងមកទាន់បានធំផងនឹងគាត់មានប្តីហើយនឹង ពីព្រោះគាត់ជាបងស្រីទី2នឹង គាត់បងអ៊ុំជិត20ឆ្នាំណោះ

ក៖  ប៉ុន្តែដូចជាអ៊ុំបងៗរបស់អ៊ុំដែរគាត់ស្លាប់ចឹងហាស?

ខ៖  អូ៎!អ្នកដែរស្លាប់ហោស?

ក៖  គាត់បានធ្វើអីគេខ្លះដែរជាមួយអ៊ុំទៅ?

ខ៖  មានអនុស្សាវរីយ៍ច្រើនណាស់ ឌុបអ៊ុំទៅរៀន
បោកខោអាវអោយអ៊ុំមានដាំបាយបញ្ចុះបាយ
បានលេងឡឹកបាយឡអីជាមួយគ្នាចឹងទៅណាស់

ក៖  ប៉ុន្តែធ្លាប់ទៅស្រែអីជាមួយគ្នាដែរទេអ៊ុំ?

ខ៖  អត់ដែរមានស្រែធ្វើផងនឹង

ក៖  ចឹងមានន័យថាអ៊ុំកើតមកនឹងអ៊ុំនៅកំពង់ចាមនឹងរហូតតែម្តងនឹង?

ខ៖  ចា៎!នៅនឹងរហូតនឹង

ក៖  អូ៎!បាទអ៊ុំ ចុះម្តាយរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឪពុករបស់អ៊ុំឈ្មោះតូក ហាង ម្តាយរបស់អ៊ុំឈ្មោះឆូវ សារុណ

ក៖  ចុះអ៊ុំមានដឹងថាឆ្នាំនឹងគាត់អាយុប៉ុន្មានដែរទេ ទាំងឪពុកនឹងម្តាយចឹងណាស់អ៊ុំ?

ខ៖  ឪពុកនឹងអាយុជាងមួយរយហើយ នឹងម្តាយក៏គាត់អាយុជាងមួយរយដែរនឹង

ក៖  ចុះគាត់បងប្អូនគ្នាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖ គាត់បងប្អូនគ្នាជាង10ឆ្នាំហើយនឹង

ក៖  ចុះម្តាយគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖  គាត់កើតនៅកោះសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម

ក៖  នឹងខាងឪពុកហោសអ៊ុំ?

ខ៖  ទាំងខាងឪពុកនឹងទាំងខាងម្តាយនឹងគាត់នៅណុងទាំងអស់គ្នានឹង

ក៖  អូ៎!ចឹងគាត់នៅនឹងទាំងអស់គ្នាតែម្តងហោសអ៊ុំ?

ខ៖  ចា៎!នឹងណុង

កៈ ចុះកាលពីឪពុករបស់អ៊ុំនៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់ធ្វើតែចំការនឹង
ប៉ុន្តែគាត់មិនដែរអោយកូនទៅនៅកោះនឹងទេគាត់អោយកូនមកនៅកំពង់ចាមនឹង
ទាំងអស់គ្នានឹង

កៈ អូ៎!គាត់នៅសំរោងយើងនឹងហោសអ៊ុំ?

ខៈ នឹងសំរោងនឹងកូនគាត់អោយនៅកំពង់ចាមមានផ្ទះនៅកំពង់ចាមនឹង
នៅរៀនពីព្រោះមានបងៗនឹងជាំអ្នកគ្រប់គ្រង

កៈ ចុះឪពុករបស់អ៊ុំគាត់មនុស្សស្លូត រឺមួយក៏កាចដែរអ៊ុំ?
ខៈ គាត់ជាមនុស្សស្លូត ប៉ុន្តែម៉ឹងម៉ាត់

កៈ ចុះម្តាយរបស់អ៊ុំវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់នៅតែចំការជាមួយតែតាយាយនឹងនៅតែពីរនាក់នឹងនៅតែផ្ទះនឹង
ផ្ទះចំការចឹងទៅហើយជួល កម្មករនឹង

កៈ ចុះម្តាយរបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ គាត់មិនជាស្លូតទេ ហើយក៏មិនជាកាចដែរប៉ុន្តម៉ឹងម៉ាត់តែម្តងនឹង

កៈ ទាំងឪពុកទាំងម្តាយមិនកាចទេប៉ុន្តែម៉ឹងម៉ាត់?

ខៈ គាត់ម៉ឹងម៉ាត់ ប៉ុន្តែមិនដែរជេរកូន រឺមិនដែរវៃកូនចៅទេប៉ុន្តែកូនចៅខ្លាចតែម្តងនឹង

កៈ អូ៎!លក្ខណៈថាគ្រាន់តែឃើញមុខខ្លាចតែម្តងហោសអ៊ុំ?

ខៈ គ្រាន់តែគាត់ក្រហែមក៏ខ្លាចដែរគ្រាន់តែគាត់ស្តោះទឹកមាត់នឹងក៏ខ្លាចដែរ

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ មែនតើ!
នៅផ្ទះកំពុងតែជួបជុំបងប្អូនលេងចូលឆ្នាំអីចឹងណាស់ដើរលេងអីនឹងគ្រាន់តែគាត់ដើរមកនឹ
ង គាត់ក្រហែមនឹងរឺស្តោះទឹកមាត់អី
ហើយយើងកំពុងតែលេងបៀរអីនឹងនាំគ្នាក្រាបអស់រលីងនឹង

កៈ អ្ហូ!ចឹងផងអ៊ុំ?

ខៈ សំរាប់កូនៗជំនាន់ក្រោយៗនឹងគ្មានខ្លាចម៉ែឪសូម្បីតែបន្តិច

កៈ ចុះអ៊ុំធ្លាប់មានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយឪពុកម្តាយរបស់អ៊ុំហាស?

ខៈ គ្មានអនុស្សាវរីយ៍អីទេក្មួយពេលដែរយើងឈឺអីចឹងគាត់ថ្នាក់ថ្នមយើង
គាត់បីយើងគាត់អោបយើងចឹង ទៅណាស់គាត់អ៊ារយើងរត់យកទៅពេទ្យចឹងទៅ

កៈ អ្ហូ!គាត់ស្រលាញ់យើងណាអ៊ុំ?

ខៈ នឹងហើយដូចថាគាត់ផ្តល់សេចក្តីសុខច្រើនណាស់ដល់កូន

កៈ ចឹងុំមានន័យថាគាត់ផ្តល់សេចក្តីស្រលាញ់ខ្លាំងដល់យើងណាអ៊ុំ?

ខៈ
និយាយពីក្តីស្រលាញ់វិញគាត់ផ្តល់អោយកូនពេញបេះដូងតែម្តងនឹងគាត់ស្រលាញ់ណាស់

កៈ ទាំងកូនទាំងអស់ណាអ៊ុំ?
ខៈ ទាំងកូនទាំងអស់នឹងអ៊ុំអាណិតណាស់
ចឹងបានអ៊ុំបានផ្សងអោយកើតជាតិណាៗអោយសូមជួបគាត់ រហូតនឹង

កៈ បាទអ៊ុំចឹង?

ខៈ ចឹងបានចូលឆ្នាំអីនឹងអ៊ុំឧទិសរហូតនឹងអោយគាត់បានកើតកន្លែងល្អចឹងទៅណាស់

កៈ
ចុះម្តាយរបស់អ៊ុំនឹងគាត់មានដែរបានប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខៈ គាត់ប្រាប់ដែរតើ!

កៈ គាត់ប្រាប់យ៉ាងម៉េចដែរទៅអ៊ុំអាចប្រាប់ខ្ញុំបានទេ?

ខៈ ដូចថាគាត់នៅក្មេងចឹងទៅគាត់បានដើរលេងទៅមានខ្មោចអីធ្វើអីចឹងទៅណាស់
ហើយបានយកគាត់ទៅលាក់នៅក្នុងព្រៃចេកហោស

កៈ អឺៗ!ម៉េចចឹងអ៊ុំ?

ខ៖ ដឹងអីទេរួចស្រាប់តែជីដូនជីតាមករកនឹង លក្ខណៈថាម្ដាយឪពុកគាត់មកដើររកចឹងទៅណាស់ ហៅដែរប៉ុន្តែវាមិនអោយឆ្លើយទេ កាលណុងគាត់នៅអាយុប្រហែលជា7ឆ្នាំ

ក៖ ខ្មោចហោសអ៊ុំ?

ខ៖ ចា៎!នៅស្រុកណុងគេហៅស្រុកម្លិច មាន់ហើរនឹង

ក៖ អ៊ូ!នៅស្រុកម្លិច មាន់ហើរ គៀនជ្រៃ រអាងនឹងហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយស្រាប់តែគាត់ទៅៗគាត់មានម្ដាយឪពុករបស់គាត់នៅណុងណាស់ស្រុកកំណើតនឹង ហើយក៏គាត់ទៅលេងចឹងទៅគេហៅវាមិនអោយឆ្លើយទេ ដល់ពេលចឹងគេលេងភ្លេងពីដើមនឹងគេហៅ ភ្លេងសៀម ហើយឥឡូវនឹងគេហៅភ្លេងពិនពាតហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ដល់ពេលដែរលេងភ្លេងសៀមគ្រប់7បទវាបានជួបយើងមកវិញ

ក៖ អ៊ូ!ឡូយអ៊ុំ?

ខ៖ ស្រាប់តែពេលណុងវាជូនមកពេលដែរមកដល់ផ្ទះនឹងយើងឃើញគាត់ចឹងគាត់បានដួលសន្លប់ចឹង ណាស់គាត់ប្រាប់រឿងនឹងគាត់បាននិយាយថាគេមិនអោយយើងឆ្លើយទេ គាត់ទៅនៅអស់7ថ្ងៃហាស ដែរទៅនៅជាមួយខ្មោចនឹងណាស់

ក៖ ប៉ុន្តែគាត់នៅលក្ខណៈយ៉ាងម៉េចដែរអ៊ុំ ហើយនៅនឹងនៅណាវិញទៅអ៊ុំ?

ខ៖ នៅជិតៗផ្ទះនឹងនៅព្រៃចេកនឹង

ក៖ ប៉ុន្តែគេមិនបានបង្ហាញអោយយើងឃើញទេ?

ខ៖ ថាមនុស្សអ្នកដែរទៅរកនឹងយើងជាកូននឹងយើងឃើញប៉ុន្តែគេមិនអោយយើងឆ្លើយទេហើ

យដូចថា យើងត្រូវលេងភ្លេងសៀមចឹងទៅ ហើយយើងបន់ស្រន់ចឹងទៅ ដូចថាជំនឿនឹងមានមែនណុងកាលពី ពេលណុងនឹង

ក៖ អូ៎!ចឹងហោសអ៊ំ?

ខ៖ ហើយនៅស្រុកណុងម្តាយឪពុករបស់អ៊ំមិនអោយអ៊ំទៅសោះតែម្តងនឹង មិនអោយទៅជាន់សោះ រហូតដល់ឆ្នាំ1979

ក៖ ចឹងបានអ៊ំបានទៅ?

ខ៖ ពេលដែរគាត់ស្លាប់អស់ចឹងទៅអ៊ំសាកទៅលេងមើលចឹងទៅប៉ុន្តែគេសាបរលាបអស់ហើយ នឹង ណាស់

ក៖ បាទអ៊ំ?

ខ៖ ពីមុននឹងកាលពីយើងនៅក្មេងៗនឹងគាត់មិនអោយយើងទៅប៉ះពាល់ស្រុកណុងទេ

ក៖ ចុះឪពុករបស់អ៊ំវិញគាត់មានដែរប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ំដែរទេ?

ខ៖ គាត់មិនដែរបាននិយាយអីសោះខាងឪពុក ដោយសារតែឪពុកម្តាយរបស់គាត់នឹងកូនចិន ចឹងមកពីស្រុកចិនតែម្តងនឹង

ក៖ អូ៎!ចឹងហោសអ៊ំ?

ខ៖ ចឹងមានអីមានតែកំសត់ស៊ីក្តាមប្រៃនឹងណាស់

ក៖ បាទអ៊ំ ចុះយាយតាខាងឪពុកនឹងអ៊ំមានបានស្គាល់ឈ្មោះគាត់ដែរទេអ៊ំ?

ខ៖ ស្គាល់ប៉ុន្តែអ៊ំមិនបានស្គាល់មុខពួកគាត់ទេ

ក៖ ចុះពួកគាត់មានឈ្មោះអីគេខ្លះដែរអ៊ំ?

ខ៖ ឪពុកគាត់ឈ្មោះតាឆូវ

ក៖ ចុះយាយវិញអ៊ំ?

ខ៖ យាយឈ្មោះអីទេភ្លេចឈ្មោះគាត់បាត់ហើយនឹង

ក៖ នឹងនៅខាងឪពុកណាអ៊ុំ?

ខ៖ ចា៎!សូម្បីតែខាងម្ដាយនឹងក៏អ៊ុំមិនទាន់ដែរនឹង

ក៖ ចុះគាត់បានកើតនៅណាអ៊ុំមានបានដឹងទេ?

ខ៖ គាត់កើតនៅស្រុកចិន

ក៖ អូ៎!គាត់កើតនៅស្រុកចិនហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយនៅណុងគាត់មកពីស្រុកចិននឹង

ក៖ ចុះយាយតាខាងម្ដាយអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ គាត់មានឈ្មោះតាតួក យាយឈ្មោះយាយពុធ

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ គាត់កើតនៅម្លិច មាន់ហើរ

ក៖ ចុះពួកគាត់អាយុប៉ុន្មានៗអ៊ុំមានបានដឹងទេ?

ខ៖ អូ៎!គាត់ចុងសឹងតែអាយុ150-160ឆ្នាំហើយនឹង

ក៖ អូ៎!គាត់អាយុច្រើនណាស់អ៊ុំ?

ខ៖ អាយុច្រើនណាស់គាត់នឹង

ក៖ តាំងពីមុនរហូតមកដល់ឥឡូវនឹងហោសអ៊ុំ?

ខ៖ ចុះបើអ៊ុំកើតមិនទាន់គាត់ផងនឹង

ក៖ ចុះអ៊ុំមកនៅខេត្តកំពង់ចាមនឹងយូរហើយមែនទេអ៊ុំ?

ខ៖ អ៊ុំមកនៅតាំងបីក្មេងមកនឹង

ក៖ ចឹងអ៊ុំមកនៅអស់រយះពេល60-70ឆ្នាំហើយណាអ៊ុំ?

ខ៖ អ៊ុំមកនៅនឹងតាំងពីឆ្នាំ1960នឹងអ៊ុំមកនៅហើយនឹងវាយូរហើយនឹង

កៈ វាអស់68ឆ្នាំអ៊ុំ?

ខៈ ចាំ!ប្រហែលជាប៉ុណ្ណឹងហើយ

កៈ ចុះអ៊ុំមានកូនចៅ រឺមួយក៏បងប្អូនណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អ៊ុំមានតែក្មួយបង្កើតនឹង

កៈ គាត់តរស់នៅណាដែរអ៊ុំ?

ខៈ រស់នៅកាលីហ្វ័រញ៉ា

កៈ ចុះគាត់ធ្វើអីគេនៅកាលីហ្វ័រញ៉ានឹងអ៊ុំ?

ខៈ ពីមុននឹងវារកចង់និយាយថាប្ដីនឹងកូនយើងបង្កើត
ហើយប្រពន្ធនឹងកូនក្មួយរបស់យើងបង្កើតដូចគ្នា

កៈ អូ៎!ចឹងគាត់យកគ្នាណាអ៊ុំ?

ខៈ ចាំ!យើងរៀបការអោយកាលពីជំនាន់ពលពតនឹងណាស់ជីដូនមួយវានឹង

កៈ បាទចឹងគាត់ការនៅពេលពលពត?

ខៈ នឹងហើយពីដំបូងនឹងអាប្ដីទៅធ្វើការនៅរាជការ
ដល់ពេលដែរប្រពន្ធទៅនៅជុំគ្នាចឹងទៅគេអោយទៅ លក់ទំនិញអីចឹងទៅណាស់

កៈ អូ៎!ចឹងទេហោសអ៊ុំ?

ខៈ ប៉ុន្ដែឥឡូវនឹងគេចាស់ៗអស់ហើយនឹង

កៈ ប៉ុន្ដែកូនចៅរបស់គាត់នឹងនៅណុងដែរទៅ?

ខៈ នឹងណុងធ្វើការងារនៅណុងទាំងអស់នឹង

កៈ ចុះស្វាមីរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះឈុម ម៉ាន់

កៈ មានឈ្មោះឈុម ម៉ាន់ ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ដែរទេអ៊ុំ?

ខ៖  អ៊ុំគ្រួសាររបស់អ៊ុំមុនផ្សេង នេះជាគ្រួសារក្រោយនឹង

ក៖  ចុះគ្រួសារក្រោយនឹងអ៊ុំ?

ខ៖  នៅថ្ងៃទី3 ខែប៉ុន្មានទេនេះភ្លេចបាត់ទៅហើយនឹង

ក៖  ប៉ុន្តែឆ្នាំវិញអ៊ុំ?

ខ៖  នៅឆ្នាំ1983នឹង

ក៖  អូ៎!នៅឆ្នាំ1983ចឹងមានន័យថាអស់35ឆ្នាំណាអ៊ុំ?

ខ៖  ចា៎!នឹងហើយ

ក៖  ចុះនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯងរឺក៏ម្តាយឪពុកជា អ្នករៀចំអោយដែរអ៊ុំ?

ខ៖
រៀបដោយចិត្តឯងនឹងគ្មានឪពុកម្តាយផងនឹងបើគាត់ស្លាប់នៅក្នុងជំនាន់ពលពតអស់ហើយនឹង

ក៖  ប៉ុន្តែមានបងប្អូនគាត់ជួយរៀបចំអោយដែរមែនទេ?

ខ៖  ចា៎!នឹងហើយបងប្អូនជួយដែរ

ក៖  ប៉ុន្តែកាលពីអ៊ុំប្រុសមកចូលស្តីដណ្តឹងអ៊ុំនឹងដូចជាមានជាជំនូនដែរទេ?

ខ៖  ជំនាន់ណុងមិនមានជាជំនូនអីប៉ុន្មានទេនឹង

ក៖  បាទចឹងហោសមីង?

ខ៖  ស្រលាញ់ចិត្តនឹងចិត្តនឹងជំនាន់ពលពតនឹង

ក៖  បើនិយាយពីប្រវត្តិស្នេហាតិចចឹងហាសអ៊ុំ
ដូចជាអ៊ុំប្រុសនឹងស្រលាញ់អ៊ុំអស់រយះពេលប៉ុន្មាន
ហើយស្រលាញ់នៅពេលណាបានគាត់មកចូលស្តីដណ្តឹងចឹងហាសអ៊ុំ?

ខ៖  គាត់ធ្វើអោយអ៊ុំបាក់ដៃគាត់បានបុកអ៊ុំអោយបាក់ដៃ

កៈ  អ៊ូ!គាត់បុកអ៊ុំហោសអ៊ុំ?

ខៈ  ចេញពី7មករាមក ឆ្នាំ1979នឹង

កៈ  បាទអ៊ុំម៉េចទៅ ប៉ុន្តែអ៊ុំមិនស្គាល់គាត់ទេ?

ខៈ  អ៊ុំមិនបានស្គាល់គាត់ទេ

កៈ  ហើយអស់រយះពេលប៉ុន្មានទៅបានគាត់ចាប់អារម្មណ៍ដែរទៅ?

ខៈ  អស់រយះពេល4ឆ្នាំដែរនឹង

កៈ  អ៊ូ!អស់រយះពេលយូរដែរហោសអ៊ុំ?

ខៈ  ចា៎!នឹងហើយ

កៈ  ចឹងបានគាត់ចូលស្តីដណ្តឹងអ៊ុំទៅ?

ខៈ  នឹងហើយ

កៈ  ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរទេអ៊ុំ លក្ខណះថាដូចជាភាសាអង់គ្លេស ថៃ វៀតណាមអីនឹង មានចេះទេអ៊ុំ?

ខៈ  វាចេះប៉ុន្តែវាភ្លេចអស់រលីងហើយនឹង កាលខ្ញុំនៅរៀននឹងរៀនអស់10-20ឆ្នាំអីដែរនឹង

កៈ  អ៊ូ!អ៊ុំរៀនបានច្រើនដែរនឹងចឹង?

ខៈ  អង់គ្លេសរៀនយូរ បើបារាំងក៏រៀនបានយូរដែរនឹង

កៈ  ចឹងមានន័យថាអ៊ុំចេះអង់គ្លេស នឹងចេះបារាំងទៀត?

ខៈ  ចា៎!ចេះតើ!អង់គ្លេសស្តាប់បានខ្លះៗ នឹងបារាំងស្តាប់បានដែរ ប៉ុន្តែបារាំងស្តាប់បានច្រើនជាង អង់គ្លេស

កៈ  ចុះភាសាចិនវិញអ៊ុំ?

ខៈ  អត់មានចេះទេនឹង ប៉ុន្តែបើនិយាយភាសាក្រចីវស្តាប់បាននឹង

កៈ  អ៊ូ!ចិនក្រចីវអ៊ុំស្តាប់បាន?

ខ៖ នឹងហើយលក្ខណៈភាសាលក់ដូរភាសាចិនក្រចីវនឹងស្ដាប់បាន ប៉ុន្តែមិនមែនភាសាកុកងឺទេណាស់ កុកងឺអត់ចេះទេនឹង

ក៖ ចុះអ៊ុំចេះអានរឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ បានទាំងអស់នឹង

ក៖ អ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ អ៊ុំជាប់មធ្យមសិក្សាបាក់ឌុបតាំងពីឆ្នាំ1972 មកម៉្លេស

ក៖ ប៉ុន្តែកាលពីអ៊ុំរៀននឹងអ៊ុំបានរៀនច្រើនសាលាមែនអ៊ុំ?

ខ៖ ខ្ញុំនាមរៀនតែនៅសាលាលីសេសីហានុមួយនឹង

ក៖ ចឹងមានន័យថាឈ្មោះសាលានឹងឈ្មោះលីសេសីហានុនឹង?

ខ៖ ចា៎!ពីដើមនឹងក៏ឈ្មោះចឹងដែរនឹង

ក៖ ចុះអ៊ុំធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាណាស់អ៊ុំមានទេ?

ខ៖ គ្មានទេបើនិយាយពីឆ្នាំ1979 មកនឹងមានតែឥឡូវនឹងសុទ្ធតែអ្នកឈឺ

ក៖ ប៉ុន្តែពួកគាត់មានឈ្មោះអីគេខ្លះដែរអ៊ុំមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខ៖ កាលពីឆ្នាំ1979 នឹងចាំដែរប៉ុន្តែឥឡូវនឹងឈឺភ្លេចអស់ហើយនឹង អ្នកគ្រូអៀក អ៊ាងហ៊្វយហាស ក្មួយស្គាល់ទេ

ក៖ អ្នកគ្រូអ៊ាង ហ៊្វយខ្ញុំមិនសូវស្គាល់ទេអ៊ុំ?

ខ៖ អត់ស្គាល់ទេហោស

ក៖ ពីព្រោះពួកគាត់ចាស់ៗអស់ហើយនឹង កាលពីខ្ញុំរៀននៅលីសេនឹងខ្ញុំរៀននៅឆ្នាំ2007-2010 ចឹងខ្ញុំមិនសូវស្គាល់គេ

ខ៖ អូ៎!ឆ្នាំ2007នឹងអ៊ុំបានចេញហើយនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ អ៊ុំបានចេញពីលិសេសីហានុហើយនឹង

កៈ  បាទចឹងខ្ញុំមិនសូវស្គាល់ដែរចឹងអ៊ុំ
ចុះអ៊ុំមានធ្លាប់ចងចាំអនុស្សាវរីយ៍អីជាមួយមិត្តភក្តិរបស់អ៊ុំកាលពី នៅក្មេងៗដែរទេអ៊ុំ
ដូចថាធ្លាប់បានធ្វើអីគេជាមួយគាត់ដែរចឹង?

ខៈ  ដូចជាភ្លេចអស់ហើយក្មួយមិនដឹងថាធ្វើអីគេទេនេះ
ពួកម៉ាក់របស់ខ្ញុំនឹងស្លាប់ជំនាន់ពលពតអស់ ហើយនឹង

កៈ  ចឹងអ៊ុំបានភ្លេចអស់ហើយណាអ៊ុំ?

ខៈ  នៅតែមួយនៅភ្នំពេញនឹងមិនដឹងថាស្លាប់រឺមួយក៏រស់ទេនឹង
និងបានមានអនុស្សាវរីយ៍ជាមួយគ្នានឹង ឈ្មោះ ច្រឹម ស៊ីដេត

កៈ  គាត់ឈ្មោះច្រឹង ស៊ីដេត?

ខៈ  ប៉ុន្តែឥឡូវនឹងក៏គាត់ចូលអាត្រេតដែរដោយសារតែគាត់ចាស់ហើយនឹង
នៅកន្លែងក្រសួងសាធារណះការដែរនឹង

កៈ  ខ្ញុំអត់សូវស្គាល់ផងអ៊ុំ ?

ខៈ  មានតែមួយនឹង

កៈ  ប៉ុន្តែអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់ដែរអ៊ុំ?

ខៈ  មានដេករៀនជាមួយគ្នា ហូបបាយហូបគុយទាវយប់ឡើងអីចឹងទៅណាស់
ទៅទិញគុយទាវយកមក ហូបជាមួយបាយកកអីចឹងទៅ
ហើយរៀនជាមួយគ្នានឹងមួយយប់ៗរៀនសឹងតែទល់ភ្លឺណាស់

កៈ  ចឹងហោសអ៊ុំខ្លាំង?

ខៈ  មិនមែនដូចក្មេងឥឡូវនឹងទេណាស់
ហើយរៀននឹងភ្លើងនឹងបើកឡើងតូចអត់អោយគេឃើញទេនឹង ខ្លាចគេរៀន

កៈ  អូ៎!រៀនតែម្នាក់ឯងចឹងទៅ?

ខៈ  រៀនតែម្នាក់ឯងនឹងខំរៀនរៀនមានម៉ោង មានការវិភាគត្រឹមត្រូវណាស់ក្មួយ

កៈ  អូ៎!ឡូយណាស់អ៊ុំ?

ខ៖ រៀនៗតែមែនទែននឹងដូចថាម៉ោងណារៀនគណិតរៀនគណិត
បើថានិយាយពីសៀវភៅគណិតវិញ
រៀនឡើងដាច់មួយសៀវភៅតែម្តងនឹងរៀនគ្មានអោយរំលងទេនឹង
ចំណោទចេញមកទំព័រទីប៉ុន្មានៗដឹង ទាំងអស់នឹង និយាយទៅដឹងតែម្តង

ក៖ ដោយសារតែសិស្សជំនាន់ណុងរៀនពូកែណាស់អ៊ុំ?

ខ៖ ចុះរៀនខ្លាចគេរៀនចេះជាងយើងនោះ
ចឹងទៅយើងរៀនចំណាំនិយាយពីចំណោទមួយៗនឹងយើងធ្វើ ឡើងអស់តែម្តងនឹង

ក៖ បាទអ៊ុំបាទ?

ខ៖
បើអ្នកគ្រូរៀនដល់មេរៀននឹងណាស់លំហាត់នៅក្នុងមេរៀននឹងយើងធ្វើទាល់តែអស់នឹង
យើងធ្វើខ្លួនឯងហាសមិនបាច់មកគ្រូប្រាប់ទេនឹង

ក៖ ចុះតាំងពីក្មេងរហូតមកដល់ពេលនេះនឹងអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំ?

ខ៖ នៅក្នុងឆ្នាំ1970 នឹងអ៊ុំប្រលងជាប់គ្រូណាស់

ក៖ ចឹងហោសអ៊ុំ?

ខ៖ នៅក្នុងឆ្នាំ1972-1975 អ៊ុំធ្វើគ្រូ ដល់ពេលដែរ1975-1979នឹងដល់អាពតណាស់

ក៖ បាទគ្រូវហើយអ៊ុំ?

ខ៖ ដល់ពេលឆ្នាំ1979-1987 នឹងធ្វើគ្រូវិញ ដល់ពេលឆ្នាំ1987
រហូតដល់អាត្រេតនឹងធ្វើការនៅមន្ទីរសាធារណះរដ្ឋខេត្ត

ក៖ អ៊ូ!បាទអ៊ុំល្អដែរនឹងអ៊ុំ?

ខ៖ ពេលដែរចេញពីគ្រូវិញនឹង

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំ?

ខ៖ ថាម៉េចដែរម្តងទៀត?

ក៖ និយាយពីការផ្លាស់ប្តូរហាសអ៊ុំ ទាំងសុខភាព ទាំងជីវភាពនឹងអ៊ុំ?

ខ៖
ជីវិតនៅក្មេងវាសប្បាយកាលពីនៅជាមួយឪពុកម្ដាយនឹងអត់មានការខ្វះខាតអីទាំងអស់នឹង
ចង់បានអីបាននឹងទាំងអស់នឹង

ក៖ តែដល់ពេលឥឡូវនឹង?

ខ៖ ដល់ពេលជំនាន់ពលពតនឹងខ្ញុំលនិយាយវាពិបាកបន្តិចនឹងណាស់

ក៖ បាទអ៊ុំចឹង?

ខ៖ ជំនាន់យើងធ្វើការជំនាន់ឆ្នាំ1979នឹងយើងធ្វើការងារវារៀងពិបាកបន្តិចនឹង
ដល់ពេលចាស់ទៅវារៀង ស្រួលវិញទៅ

ក៖ អូ៎!បាទអ៊ុំមានកូនចៅចិញ្ចឹមណោះអ៊ុំ?

ខ៖ ដល់ពេលដែរអាត្រេតទៅស្រួលវិញដែរនឹង មានចៅតែមួយនឹង

ក៖ ចុះអ៊ុំធ្លាប់បានបើកអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខ៖ មិនដែរទេនឹង

ក៖ ចុះអ៊ុំធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា គោ ក្របីអីដែរទេអ៊ុំ?

ខ៖ កាលមុនមានចិញ្ចឹមដែរប៉ុន្តែពេលដែរចិញ្ចឹមចឹងទៅវាមិនកាកកបនឹងណាស់

ក៖ ចិញ្ចឹមអីគេដែរអ៊ុំ?

ខ៖ ខ្ញុំចិញ្ចឹមមាន់

ក៖ ចុះពេលដែរអ៊ុំចិញ្ចឹមមាន់នឹងលក្ខណះជាកសិដ្ឋាន
រឺមួយអ៊ុំចិញ្ចឹមលក្ខណះជាគ្រួសារដែរអ៊ុំ?

ខ៖ ហេ៎!កាលណុងចិញ្ចឹមធំដែរនឹងវណ្ណី

ក៖ ចឹងមានន័យថាជាលក្ខណះកសិដ្ឋានហោសអ៊ុំ?

ខ៖ ទេមិនមែនលក្ខណះគ្រួសារទេប៉ុន្តែធំដែរនឹង

ក៖ វាលក្ខណះជាកសិកម្មហើយចឹងប៉ុន្តែគ្រាន់តែថាតូចណោះអ៊ុំ?

ខ៖ ប៉ុន្តែចិញ្ចឹមទៅវាចេះតែអត់កាកកបនឹង ហើយយ៉ាងណាមួយគិតថាខ្មែរយើងមិនសមណាធ្វើអញ្ចឹងទេ ណាសត្វចឹងណាស់យើងនឹកឃើញដល់បាប បុណ្យណាស់

ក៖ អ៎ុ!អ៊ុំគិតចឹងហោសអ៊ុំ?

ខ៖ ដល់ពេលចឹងទៅខ្ញុំឈប់ចិញ្ចឹមទៅណាស់

ក៖ ចុះអ៊ុំគិតថាអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ ខ្ញុំហូបតែត្រីទេនឹង

ក៖ ចឹងអ៊ុំចូលចិត្តត្រី?

ខ៖ ខ្ញុំចូលចិត្តតែត្រីជាងគេនឹង

ក៖ ចុះបើចង់និយាយថាសម្លម្ជូរ ការីអីដែរអ៊ុំគិតថាអ៊ុំចូលចិត្តចឹងហាស?

ខ៖ ខ្ញុំចូលចិត្តកកូរនឹង

ក៖ អូ៎!អ៊ុំចូលចិត្តកកូរហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយចូលចិត្តតែកកូរនឹង

ក៖ ចុះតាំងពីក្មេងហាអ៊ុំ តើអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះដែរអ៊ុំដូចជាលាក់កន្សែង ចោលឈូង បោះអង្គុញ ទាញព្រាត់អីចឹងហាសអ៊ុំ?

ខ៖ ចូលចិត្តលេងចោលឈូង

ក៖ អូ៎!អ៊ុំចូលចិត្តលេងល្បែងចោលឈូង ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខ៖ អត់ចេះទេ ចេះតែងំៗៗនៅចង្ក្រាននឹង

ក៖ ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរទេអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតើ!

ក៖ លក្ខណៈបទបុរាណ រឺបទសម័យដែរអ៊ុំ?

ខ៖  បទបុរាណ បទស៊ិនស៊ីសាម៉ុត

ក៖  ចុះអ៊ុំចូលចិត្តមើលយីកេ រឺមួយល្ខោនអីទេអ៊ុំ?

ខ៖  អត់ចូលចិត្តសោះនឹង

ក៖  កាលពីដើមគេចូលចិត្តមើលហីអ៊ុំ?

ខ៖  ពីដើមនឹងក៏មិនចូលចិត្ត ចង់និយាយថាគេចូលចិត្តប៉ុន្តែយើងមិនចូលចិត្តទេ

ក៖  ចុះអ៊ុំមាននរណាគេម្នាក់នៅក្នុងផ្ទះរបស់អ៊ុំ រឺក៏នៅក្នុងក្រុមគ្រួសាររបស់អ៊ុំ រឺបងប្អូនអ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  លក្ខណៈថាភ្លេងពិនពាត ភ្លេងខ្មែរអីចឹងអ៊ុំ?

ខ៖  អត់ដែរមានទេ

ក៖  ភ្លេងការអីក៏អត់មានដែរណាអ៊ុំ?

ខ៖  អត់មានទេ

ក៖  ចុះផ្ទះរបស់អ៊ុំមានលក្ខណៈបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស ដូចជាពីក្មេងផ្ទះ ម៉េច ហើយឥឡូវនឹងផ្ទះម៉េច?

ខ៖  ពីក្មេងផ្ទះឪពុកម្តាយហោស?

ក៖  បាទអ៊ុំ?

ខ៖  ពីមុនធំណាស់មានសសរ4ជួរនឹង មានដំរីបោលចូលរលុងនឹងណាស់ផ្ទះពិតនឹង

ក៖  អ៎ូ!ផ្ទះពិតហោសអ៊ុំ?

ខ៖  យើងមានពោតនៅលើផ្ទះនឹងហាស គេមានឡានជិះចូលហើយដាក់ពោតបានទៀតធំៗហើយខ្ពស់ៗ ហាសណាស់ហើយពោតកាលណុងមួយរយប៉ាវ ធំៗហាសណាស់

ក៖  ចុះឥឡូវនឹងវិញអ៊ុំ?

ខ៖  ឥលូវនឹងនេះផ្ទះអ៊ុំផ្ទះនឹងជួលអោយពួកបរទេសនឹងដែរ

ក៖  អូ៎!បាទអ៊ុំ ចុះផ្ទះរបស់អ៊ុំនឹងនរណាគេដែរជាអ្នកសាងសង
អ៊ុំជួលគេរឺមួយអ៊ុំជាអ្នកសាងសងដោយខ្លួន ឯងដែរអ៊ុំ?

ខ៖  អ៊ុំធ្វើខ្លួនឯងនឹង

ក៖  ចុះនរណាគេជាអ្នកធ្វើដែរអ៊ុំ?

ខ៖  យើងជួលជាងធ្វើនឹង

ក៖  អូ៎!ជួលជាងហោសអ៊ុំ ខ្ញុំស្មានតែប្តីរបស់អ៊ុំគាត់ចេះធ្វើផ្ទះដែរ?

ខ៖  អត់ទេយើងជួលជាងនឹង

ក៖  ចុះអ៊ុំគិតអីដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖  ធ្វើជាគ្រូ

ក៖  អ៊ុំធ្វើជាគ្រូបង្រៀនណាអ៊ុំ?

ខ៖  បង្រៀនខាងគណិតវិទ្យានឹងស្ទាត់ជំនាញជាងគេនឹង

ក៖  ចឹងមានន័យថាអ៊ុំពូកែខាងបង្រៀនគណិតវិទ្យា?

ខ៖  នឹងហើយអ៊ុំខាងនឹង

ក៖  ចុះអ៊ុំគិតថាម្តាយឪពុករបស់អ៊ុំនឹងគាត់ធ្លាប់បង្រៀនពីជំនាន់អីទៅអ៊ុំដែរទេ?

ខ៖  បង្រៀនអីទៅ?

ក៖  លក្ខណះថាវេញវល្លិ៍ ក្រូស្កត្នោត ធ្វើផ្តៅ?

ខ៖  ដឹងអោយតែរៀនតែម្តងនឹង

ក៖  ចឹងអ៊ុំរៀនតែមួយមុខទេណាអ៊ុំ?

ខ៖  ដឹងអោយតែរៀននឹង គាត់ថាធ្វើស្រែចំការនឹងវាពិបាកណាស់ធ្វើស្រែចំការនឹង

ក៖  អូ៎!ចឹងហោសអ៊ុំ?

ខ៖ ដឹងថាអោយតែរៀននឹងតែម្តងនឹងកូនមាន7នាក់នឹងអោយទៅតែរៀននឹង សុខចិត្តនឹងលំបាកតែ2នាក់ប្តីប្រពន្ធគាត់នឹងអោយតែកូនបានរៀន

ក៖ និយាយពីការលំបាកវិញចុះអ៊ុំគិតថាតាំពីក្មេងរហូតមកដល់ពេលនេះហាស អ៊ុំគិតថាធ្លាប់មានការលំបាកអីគេដែរអ៊ុំ?

ខ៖ មានតាំងពីឆ្នាំ1979 មកនឹង

ក៖ ចុះមានការលំបាកអីគេខ្លះដែរអ៊ុំគិតថាពិបាកហាស?

ខ៖ តាំងពីឆ្នាំ1979នឹង

ក៖ ចុះក្មេងមានការលំបាកអីទេ?

ខ៖ ពីក្មេងនឹងគ្មានការលំបាកអីទេ

ក៖ ចុះបើកាលពីជំនាន់ពលពតនឹងអ៊ុំការលំបាកអីគេខ្លះដែរទៅអ៊ុំ អ៊ុំអាចប្រាប់ខ្លះៗមួយចំនួនបានដែរទេ?

ខ៖ ពលពតនឹងពិបាករកលេខដាក់គ្មានទេនឹង យ៉ាងណាមួយហូបវាមិនឆ្អែតទៀត ណាមួយពេលដែរ ដេកនឹងពេលដែរគោះជួងនឹងអោយយើងទៅធ្វើការងារទៅ

ក៖ ចុះបើយើងទៅមិនទាន់ធ្វើម៉េចទៅ?

ខ៖
បើយើងមិនបានទៅធ្វើការចឹងវាដាក់កំនត់ថាជីរណ្តៅដីចឹងណាស់អោយបានមួយគិបបើ យើងធ្វើមិន បានទេមិនអោយយើងឈប់ទេនឹង

ក៖ ប៉ុន្តែយើងទៅគ្នាច្រើនមែនទេអ៊ុំ?

ខ៖ អត់ទេវាគិតម្នាក់ប៉ុណ្ណឹងតែម្តងនឹង

ក៖ អូ៎ៗចឹងគេមានកំណត់ចំនួនមនុស្សទៅ?

ខ៖ នឹងហើយដូចថាគេធ្វើហើយប៉ុណ្ណាយើងឈប់ត្រឹមនឹងទៅណាស់

ក៖ អូ៎!ចឹងយើងត្រូវខំធ្វើវាអោយលឿនទៅចឹង?

ខ៖  នឹងហើយស្ទូងដកក៏ចឹងដែរយើងធ្វើរួចត្រឹមណាយើងឈប់ទៅ

ក៖  អូ៎!ចឹងគ្រប់ការងារវាកំណត់អោយយើងចឹងទៅ?

ខ៖  នឹងហើយវាកំណត់អោយយើងចឹងតែម្ដងនឹង

ក៖  ពេលណុងរបបអាហារនឹងមានស្អីគេដែរអ៊ុំ?

ខ៖  ហូបបបរនឹង

ក៖  អូ៎!ហូបបបរហោសអ៊ុំ?

ខ៖  នឹងហើយអ៊ុំទៅនៅណុងអ៊ុំចូលចិត្តខាងសិល្បះ
ពីមុនមកអ៊ុំចូលចិត្តខាងរាំច្រៀងអីចឹងណាស់

ក៖  អូ៎!ចឹងហោសអ៊ុំឡូយអ៊ុំ?

ខ៖  ដល់ពេលចឹងទៅគេអោយអ៊ុំចូលសិល្បះ
ដល់ពេលណុងទៅអ៊ុំបានបង្រៀនអោយវាបទអ្នកដែរចៃក បបរនឹងវាឈ្មោះល្ងួតហោស

ក៖  បាទចឹងម៉េចទៅអ៊ុំ?

ខ៖  វាដួសមួយកំប៉ោយចឹងទៅ វាដួសហើយវាកាយអ៊ុំប្រាប់ក្មេងអោយច្រៀងនឹងណាស់
ព្រឹកមួយកំប៉ោយនឹងល្ងាចមួយកំប៉ោយ ដួសអោយកៀសហើយកាយផង

ក៖  អូ៎!ដួសហើយកាយផងហោសអ៊ុំ?

ខ៖  ដល់ពេលយូរៗទៅវាចង់យកអ៊ុំទៅកសាងនឹងណាស់

ក៖  អូ៎!គេខឹងនឹងអ៊ុំហោសអ៊ុំ?

ខ៖  នឹងហើយបានវាឈប់អោយច្រៀងបទនឹងលេងនឹងព្រឹកមួយកំប៉ោយ
ល្ងាចមួយកំប៉ោយពូល្ងួតចៃក អោយកៀសហើយកាយផង

ក៖  អូ៎!ចូលចិត្តច្រៀងហោសអ៊ុំ?

ខ៖  នឹងហើយយើងនិយាយកៀសហើយកាយផងនឹង
ប៉ុន្តែហូបបបរហូតនឹងគំរស្គាល់ជាតិបាយណាស់

កៈ ប៉ុន្តែពេលណុងគេអោយជំលាសទៅណាដែរទៅអ៊ុំ?

ខៈ អោយទៅបាត់ដំបង

កៈ អូ៎!ទៅបាត់ដំបងហោសអ៊ុំ?

ខៈ ចា៎!អោយទៅណុង

កៈ ប៉ុន្តែអ៊ុំបានធ្វើអីគេខ្លះទៅពេលណុង?

ខៈ អោយទៅធ្វើស្រែចុះមិនដឹងថាស្គាល់ស្រែយ៉ាងម៉េច
នឹងស្រូវយ៉ាងម៉េចផងនឹងតែអាចធ្វើកើត ធ្វើស្រែនឹងធ្វើនៅរោងបាយ
ធ្វើនៅសិល្បះធ្វើច្រៀនកន្លែងដែរនឹង

កៈ អូ៎!ចឹងអ៊ុំធ្វើច្រើនកន្លែងដែរចឹង?

ខៈ កាលណុងអ៊ុំនៅអាយុម្ភៃជាងនឹង

កៈ អូ៎!អ៊ុំធំហើយណាអ៊ុំ?

ខៈ ខ្ញុំធមហើយនឹង

កៈ ចឹងអ៊ុំពេលណុងពេញកំលាំងហើយណាអ៊ុំ?

ខៈ ពេញកំលាំងនឹងណា

កៈ ចុះបងប្អូនរបស់អ៊ុំគេអោយទៅណាដែរអ៊ុំ?

ខៈ បែកគ្នាទាំងអស់នឹងអ្នកខ្លះទៅចំការលើ អ្នកខ្លះទៅខាងមេម៉ត់ចឹងទៅ
ប៉ុន្តែគេយកទៅវៃចោលទាំង អស់នឹងនៅចំការលើនឹងមួយគ្រួសារ
ពីរគ្រួសារគេយកទៅវៃចោលទាំងអស់នឹង

កៈ អូ៎!ចឹងហោសអ៊ុំ?

ខៈ ទៅមេម៉ត់នឹងមានច្រើនគ្រួសារណាស់
ចេះតែទៅៗចឹងហើយមិនមែនយើងចង់ទៅខ្លួនឯងទេណាស់ គេអ្នកតំរង់ទិសអោយនឹង

កៈ ចឹងមានន័យថាគេអោយយើងទៅ?

ខ៖  នឹងហើយមិនមែនថាយើងចង់ទៅនឹងតាមតែអំពើចិត្តយើងទេណាស់ វាតំរង់ទិសកាំភ្លើងវាត្រូវតែផ្ទុង តែម្តងនឹងវាអោយទៅងាកទៅខាងណាមិនបានទេនឹង ចឹងបានអ៊ុំទៅនឹង ខំអីនឹងអ៊ុំមកកំពង់ចាមវិញបាត់ ទៅហើយនឹង

ក៖  ប៉ុន្តែគេមានឡានអោយយើងទៅមែនទេអ៊ុំ?

ខ៖  អត់ទេដើរនឹង

ក៖  ស្លាប់ដើរពីកំពង់ចាមទៅហោសអ៊ុំ?

ខ៖  អំដើរពីកំពង់ចាមទៅដល់តាំងឬស្សីព្រៃនិចនៅខេត្តតាកែវហោស

ក៖  ចឹងអ៊ុំហោស?

ខ៖
ពេលដែរតៅដល់ណុងគេបានហៅអោយទៅនៅវត្តក្រពើទើពេលដែរទៅដល់វត្តនឹងទៅក៏ទៅទៀត

ក៖  ទៅដល់បាត់ដំបងនឹងទៅ?

ខ៖  អ៊ុំវាប្រុងយកទៅសំលាប់ចោលតើ!ពីព្រោះវារើសណាស់ រើសដូចថាប្រជាជនផ្ញើរចឹងណាស់គេថា យកទៅសំលាប់ចោលប្រជាជនគេថាប៉ុន្តែយើងមិនដឹងទេនឹងបានយកទៅបាត់ដំបងនឹងអូ យើងបានស៊ី ឆ្អែតនឹងហោស

ក៖  ប៉ុន្តែបាត់ដំបងនឹងយកទៅក្រោយគេណាអ៊ុំ?

ខ៖  ចាំ!ទៅក្រោយគេនឹង

ក៖  ជាតំបន់យើងទៅក្រោយគេចឹង?

ខ៖
ដល់ហើយនឹងវាបានយកទៅចាក់ចោលនៅឯជើងភ្នំហោសយើងមិនដែរស្គាល់សោះទាំងយប់តែម្តង នឹង ហើយចេះតែនាំគ្នាត្រូសត្រាយទៅនេះទៅនោះចឹងទៅដល់ភូមិព្រះពន្លឺ

ក៖  នៅស្រុកបាត់ដំបងនឹងហោសអ៊ុំ?

ខ៖  ចា៎!នៅស្រុកក្រឡ

ក៖  ចុះពីកំពង់ចាមទៅតាកែវចឹងយើងដើរចំណាយពេលប៉ុន្មានថ្ងៃទៅអ៊ុំ?

ខ៖  ទេអ៊ុំចេញពីភ្នំពេញទេនឹង

ក៖  អូ៎!អ៊ុំចេញពីភ្នំពេញទេហោសអ៊ុំ ប៉ុន្តែអ៊ុំចំណាយពេលប៉ុន្មានថ្ងៃទៅបានទៅដល់ណុង?

ខ៖  វាយូរដែរមិនដឹងថាប៉ុន្មានថ្ងៃទេ
កាលពីជំណុងយើងមិនដឹងថារកពេលវេលាណារាប់មិនចេញទេនឹង
ហើយយើងមិនហ៊ានលឿន
ហើយវាប្រាប់ថាអោយយើងទៅតែ3ថ្ងៃទេវាអោយមកវិញនឹងណាស់

ក៖  អូ៎!បាទអ៊ុំ?

ខ៖  ដល់ពេលចឹងទៅយើងជឿសំដីវាចឹងទៅ

ក៖  ចឹងយើងមិនហ៊ានដើរលឿនទេចឹង?

ខ៖  ថាកុំអោយឆ្ងាយពីផ្ទះតែ3ថ្ងៃទេស្រួលយើងត្រលប់មកវិញ 3ថ្ងៃមិនឃើញមក
មួយអាទិត្យមិនឃើញ មកដើរមករាប់ខែដែរនឹងហាស

ក៖  អូ៎!យូរដែរអ៊ុំ?

ខ៖  ប៉ុន្តែពេលដែរអ៊ុំចេញពីបាត់ដំបងមកវិញនឹងអ៊ុំដើរក្នុងព្រៃនឹងឆ្នាំ1979
អ៊ុំដើរចេញមកដល់អំលាំងនៅ ភ្នំពេញនឹងអស់ជិត2ខែ

ក៖  ដើរពីបាត់ដំបងមកនឹង?

ខ៖ ចា៎!មកដល់អំលាំងនឹង

ក៖  ដល់អំលាំងហោសអ៊ុំ?

ខ៖  ចា៎!នឹងដើរក្នុងព្រៃតែម្តងនឹង យប់ឡើងដើរថ្ងៃឡើងសំងំដេកហើយនឹង

ក៖  អូ៎!ចឹងយើងត្រូវធ្វើចឹងជារៀងរាល់ថ្ងៃចឹងទៅ?

ខ៖  ធ្វើចឹងទៅពេលនឹងដើរចេញពីអាពតចឹងទៅ

កៈ ប៉ុន្តែដើរនឹងមនុស្សច្រើនរឺយ៉ាងណាដែរមីង?

ខៈ មានមនុស្សច្រើនដែរ ហើយមិនដឹងថាមានអ្នកស្លាប់អស់ប៉ុន្មានអីប៉ុន្មានទេនឹង

កៈ មានអ្នកស្លាប់ដែរនឹង?

ខៈ មានអ្នកស្លាប់នឹងប៉ុន្តែមានអ្នកស្លាប់នឹងអស់គ្នាច្រើន ហើយពេលដែរយើងមកជួបយួនមករំដោះនឹងក៏ មានគ្នាតិចដែរនឹង ចង់និយាយថាយើងត្រូវតែសំរុកចូលហាស ទោះថាត្រូវគេបាញ់យ៉ាងណាក៏ត្រូវតែទៅដែរនឹងណាស់

កៈ អ៊ូ!ចឹងយ៉ាងម៉េចទៅអ៊ុំ?

ខៈ ដូចថាអាពតក៏បាញខាងយើងក៏បាញដែរនឹង

កៈ បាទអ៊ុំចឹង?

ខៈ ប៉ុន្តែមុជក្បាលរត់មកតែម្តងនឹង

កៈ ប៉ុន្តែពួកគាត់ស្លាប់នឹងដោយសារតែអីគេដែរអ៊ុំដោយសារតែអត់បាយអត់ទឹករឺមួយយ៉ាងណាដែរអ៊ុំ?

ខៈ កាលពីជំនាន់ណុងនឹងអ៊ុំក៏មិនដឹងថា និយាយទៅអ៊ុំយកតែមួយជីវិតខ្លួនឯងនឹងសូម្បីតែអត់បាន រឺក៏អត់ទឹកក៏មិនដឹងដែរនឹង

កៈ ចឹងអ៊ុំមិនបានដឹងទេ?

ខៈ នឹងហើយទោះត្រូវគ្រាប់កាំភ្លើងក៏មិនដឹងដែរនឹង និយាយទៅយើងខំយកតែរស់នឹង

កៈ ប៉ុន្តែពេលដែរយើងដើរនឹងយើងដើរតែគ្នាយើង រឺមួយវាដើរមកជាមួយយើងដែរអ៊ុំ?

ខៈ យើងដើរតែគ្នាយើងតើ!

កៈ ចុះយើងម៉េចស្គាល់ផ្លូវដែរអ៊ុំ?

ខៈ ទេមានអ្នកនាំផ្លូវនឹង

ក៖ ចឹងមានន័យថាមានអ្នកនាំផ្លូវធ្វើអ្នកនាំមួយដែរហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយអ្នកដែរនាំនឹងបែបគេមើលតែផ្កាយទេមិនដឹងទេនឹង

ក៖ ប៉ុន្តែគេដឹងថាទៅខេត្តណាៗគេទៅដល់ណាអ៊ុំ?

ខ៖ គេមើលតែនៅលើនឹងទេ មិនដឹងទេអត់ដឹងថាគេដឹងតារយះអីដែរនឹង

ក៖ យើងក៏ដើរតាមគេចឹងទៅ?

ខ៖ ចេះតែដើរតាមគេចឹងទៅ

ក៖ ទៅដល់ណាៗគេជូនទៅដល់ណាចេះតែជូនទៅៗៗ?

ខ៖ ទៅណាចេះតែទៅៗ ទោះទៅស្លាប់ក៏ចេះតែទៅៗនឹង

ក៖ អូ្ន!ចឹងណាអ៊ុំ?

ខ៖ ពីព្រោះតែយើងអស់សង្ឃឹមហើយនឹង

ក៖ ប៉ុន្តែពេលណុងយើងលែងខ្វល់ហើយនឹងតាមតែគេចឹងទៅ?

ខ៖ នឹងហើយលែងខ្វល់តាមតែគេចឹងទៅ ហើយមានស្រីម្នាក់មកទោះទាយហាស

ក៖ យ៉ាងម៉េចដែរទៅអ៊ុំ?

ខ៖ ចិនសែហាសគេនិយាយម៉ោងនេះអោយដេក ម៉ោងនេះនៅស្ងៀម ម៉ោងនេះអោយសំរាកចឹងទៅ

ក៖ គាត់ពូកែហើយចឹង?

ខ៖ គាត់ពូកែណាស់ស្រីម្នាក់នឹង

ក៖ ខ្ញុំលឺថាការពីជំនាន់ណុងគេពូកែៗណាស់អ៊ុំ?

ខ៖ ចា៎!ម្នាក់ស្រីនឹងគេអោយជិះរទេះគោម្នាក់ស្រីនឹង ស្រីនឹងថាចេញយើងចេញ ស្រីនឹងថាឈប់យើង ទាំងអស់គ្នានឹងត្រូវតែឈប់តែម្តងនឹង

ក៖ អូ្ន!និយាយចឹងស្រីនឹងខ្លាំងហើយចឹង?

ខ៖ អត់ទេពេលដែរអ៊ុំឆ្លងកាត់ពីអាពតនឹងប្រហែលជាខ្ទង់50-60នាក់ប្រហែលជាមើលទៅនឹង

ក៖ អូ៎!ចឹងច្រើនដែរអ៊ុំ?

ខ៖ គេបាញ់គេបាញ់ចំរុះគ្នានឹងម្ខាងខាងយើងបាញ់ឡើងលើទៅខាងអាពតនឹងបាញ់សំលាប់យើងចោល តែម្តងនឹង

ក៖ គេបាញ់យើងយកតែម្តងហោសអ៊ុំ?

ខ៖ ចា៎!អារបៀបបាញ់ចុះក្រោមតែម្តងនឹង

ក៖ ចុះនៅពេលដែរដាច់ពលពតនឹងអ៊ុំគិតថាមានការលំបាកអីគេដែរទៅអ៊ុំអ៊ុំថាលំបាកខ្លាំងដែរហោសអ៊ុំ?

ខ៖ លំបាកដូចថាយើងមកនឹងអស់រលីងតែម្តងនឹង ផ្ទះសំបែងក៏អស់រលីង គេដុតគេឈូសអស់នឹង ហើយយើងក៏មិនមានមុខរបរអីរកស៊ីទៅ ដល់ពេលចឹងគ្រូចាស់ៗពីដើមគេស្គាល់បានគេហៅអោយទៅធ្វើ គ្រូចឹងទៅណាស់

ក៖ ចឹងហោសអ៊ុំ?

ខ៖ ធ្វើគ្រូចឹងទៅអ្នកចេះច្រើនបង្រៀនអ្នកចេះតិចចឹងទៅអ៊ុំក៏ចង់រកស៊ីដែរកាលណុងអ៊ុំលក់អីនេះនោះ ដែរនឹងតិចតួចដែរនឹង

ក៖ អូ៎!បាទអ៊ុំម៉េចទៅ?

ខ៖ ប៉ុន្តែវាមិនប៉ុន្មានទេគ្រូនឹងគេធ្វើជាប់ៗហាសណាស់

ក៖ រហូតមកដល់ឥឡូវនឹងអ៊ុំការលំបាកអីគេដែរទេអ៊ុំ?

ខ៖ ឥឡូវនឹងគ្មានអីទេគ្រាន់តែថាវាឈឺនឹង

ក៖ អូ៎!អ៊ុំពិបាកត្រង់អ៊ុំឈឺហោសអ៊ុំ?

ខ៖ អ៊ុំឈឺពេញខ្លួនចឹងទៅដូចថាអ៊ុំញ័រពេញខ្លួននឹងទៅណាស់

ក៖ ឈឺអីគេដែរអ៊ុំ?

ខ៖  អត់ដឹងទេ អង្គុយចឹងទៅវាចេះតែញ័រ លក្ខណះលើសឈាម នឹងទឹកនោមផ្អែមនឹង

ក៖  នឹងលក្ខណះថាជំងឺចាស់ហោសអ៊ុំ?

ខ៖  នឹងមិនមែនលក្ខណះថាជំងឺចាស់ទេណាវណ្ណី ដូចជាទឹកនោមផ្អែមអីតាំងពីក្មេងអីនឹង?

ក៖  ដូចថាតាំងពីក្មេងមកហោសអ៊ុំលក្ខណះទូទៅនឹងហោសអ៊ុំ?

ខ៖  ចា៎!ប៉ុន្តែអ៊ុំឈឺ4ឆ្នាំហើយនឹង

ក៖  ចុះគិតថាអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖  ឆ្លងកាត់រឿងអីគេដែរ?

ក៖
ទាំងពីក្មេងរហូតមកដល់ឥឡូវនឹងអ៊ុំគិតថាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅអ៊ុំ?

ខ៖  ដូចជាពិបាកឆ្លើយម៉េស

ក៖  ដូចថាអ៊ុំមានការតស៊ូរឺមួយអីផ្សេងៗដែរអ៊ុំគិតថាអាចឆ្លងកាត់ហាស
អ៊ុំអាចពុះពារឧបសគ្គហាស?

ខ៖  ដូចមិនដឹងថាម៉េចទេនេះមិនដឹងថាឆ្លងកាត់ដោយរបៀបណា

ក៖  អូ៎!អត់អីទេអ៊ុំចឹង
ចុះពេលណាដែរអ៊ុំគិតថាជាពេលដែរអ៊ុំសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរហោសអ៊ុំ?

ខ៖  ក្នុងមួយជីវិតដែរសប្បាយជាងគេហោស?

ក៖  បាទអ៊ុំបាទ?

ខ៖  បើនិយាយអោយចំនឹងគឺអ៊ុំពេញវ័យនៅសម័យលុនណុលនឹង

ក៖  នឹងអ៊ុំសប្បាយជាងគេហើយ?

ខ៖  នឹងសប្បាយជាងគេបំផុតតែម្តងនឹង

កៈ ម៉េចចឹងអ៊ុំ?

ខៈ សប្បាយនឹងប៉ុន្តែបើនិយាយទៅវាប៉ះពាល់

កៈ អូ!ចឹងហោសអ៊ុំបើចឹងមិនបាច់និយាយទេអ៊ុំ?

ខៈ ចា!នឹងហើយ

កៈ
ចុះអ៊ុំគិតថាតាំងពីក្មេងមកនឹងអ៊ុំគិតថាធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងអ៊ុំចង់ធ្វើអីដែរទេនឹង?

ខៈ ស្រម៉ៃដែរប៉ុន្តែមិនបានសំរេចបានតាមសេចក្តីប្រាថ្នាទេនឹង

កៈ អ៊ុំចង់ធ្វើអីគេដែរអ៊ុំ?

ខៈ ខ្ញុំចង់ធ្វើជាអ្នកតំណាងរាស្ត្រ

កៈ អូ!អ៊ុំចង់ធ្វើធំដែរណាអ៊ុំ?

ខៈ ចង់ធ្វើតំណាងរាស្ត្រនឹង
តាំងបីតូចមកតែម្តងនឹងប៉ុន្តែវាមិនបានសំរេចតាមគោលបំណង

កៈ អូ!ចឹងហោសអ៊ុំ?

ខៈ ទៅចូលម្តងហើយតើ!នៅឆ្នាំ1979នឹង

កៈ ចុំម៉េចទៅអ៊ុំ?

ខៈ បងប្អូនទាំងអស់គ្នានឹងគេនិយាយថាកុំទៅខាងនយោបាយអីនឹង
វាជាប់គុកមិនដឹងខ្លួនទេនឹងវាចឹងឯងបានមិនទៅ

កៈ ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចោជំនាន់ក្រោយៗហាស
តើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ ចងថាកូនចៅនឹងចង់តែអោយវាធ្វើពេទ្យនឹងនិយាយអោយត្រង់នឹង

កៈ ចង់អោយធ្វើពេទ្យណាអ៊ុំ?

ខះ  អោយរៀនអោយបានធ្វើពេទ្យទៅបានបើកវ៉ាមស៊ីខ្លួនឯងលក់ថ្នាំពេទ្យទៅណាស់

កះ  ចឹងមានន័យថាអ៊ុំស្រលាញ់ខាងពេទ្យណាអ៊ុំ?

ខះ  យើងស្រលាញ់ខាងនឹងបើអ៊ុំឈឺហាស បើពេលណុងមានពេទ្យម្នាក់
កាលពីនៅក្មេងនឹងមានបងស្រី 2នាក់ធ្វើពេទ្យហោស

កះ  បាទចឹងអ៊ុំ?

ខះ  គ្រាន់តែម្ដាយរបស់អ៊ុំទៅពេទ្យភ្លាមនឹងគេថាហោសមើលម្ដាយអ្នកគ្រូពេទ្យនោះផងនឹង
នោះចូលមកហើយជួយមើលម្ដាយអ្នកគ្រូពេទ្យនោះផង
គ្រាន់តែលឺប៉ុណ្ណឹងមានមនុស្សទៅតែម្ដងនឹង

កះ  អូ៎!ចឹងមានន័យថាគេខ្វល់តែខាងរឿងខ្សែគ្នាគេអីចឹងហាសណាអ៊ុំ?

ខះ  ចា៎!ថាចឹងក៏បានដែរនឹង
ដល់ពេលចឹងនឹកឃើញដល់កូនចៅពេលដែរយើងឈឺចឹងទៅចាស់គេ
ប្រងើយកណ្ដើយហាស

កះ  បាទចឹងហោសអ៊ុំ?

ខះ  ស្រម៉ៃឃើញកាលណុងហាសណាស់

កះ  បាទចឹងវាពិបាកដែរ?

ខះ  ចឹងហើយនឹកឃើញដល់កូនចៅនឹង ចៅរៀនស្រីៗនឹងរៀនខាងវ៉ាមស៊ីចឹងទៅ
ពេលដែរធំឡើងចឹង ទៅបើកវ៉ាមស៊ីលក់ចឹងទៅវាគ្រាន់បើដែរនឹង

កះ  ចុះបើចង់អោយគាត់ជៀសវៀងវិញតើអ៊ុំចង់អោយគាត់ជៀសវៀងអីគេដែរអ៊ុំ?

ខះ  ជៀសវៀងរាំច្រៀងនឹង បើចង់អោយជៀសវៀងនឹង

កះ  អត់ទេអ៊ុំលក្ខណះថាអោយជៀសវៀងពីជក់គ្រឿងញៀនអីចឹងហាសអ៊ុំ?

ខះ  អូ៎!អានឹងមិនអោយទេនឹង

កះ  បាទបើសិនជាចង់អោយជៀសវៀងវិញតើអ៊ុំចង់អោយជៀសវៀងអីគេខ្លះដែរអ៊ុំ?

ខ៖  ជក់គ្រឿងញៀនអីនឹងអូអត់អោយសោះហើយនឹង
និយាយរួមអ្វីដែរជាអំពើអបាយមុខគឺមិនអោយ ដាច់ខាតនឹងខ្ញុំស្អប់ណាស់នឹង

ក៖
នឹងហើយអ៊ុំលក្ខណះអ៊ុំចង់អោយកូនចៅជំនាន់ក្រោយៗរបស់អ៊ុំជៀសវៀងដែរចឹងហាសអ៊ុំ
លក្ខណះងោយគាត់គេចផុតចឹងហាសអ៊ុំ?

ខ៖  គេចផុតទាំងអស់នឹងល្បែងស៊ីសងនឹង
គ្រឿងញៀនអីនឹងប៉ុន្តែកូនចៅរបស់អ៊ុំនឹងអត់មានទេ គេល្អណាស់ប៉ុន្តែថាមិនអួតទេណាស់

ក៖  បាទអ៊ុំបាទអ៊ុំ?

ខ៖  គ្រាន់តែថាវាអាចប្រដៅបានកូនប្រុសមួយនឹង
អាមួយកូនប្រុកមួយនៅភ្នំពេញនឹងមានតែមួយនឹងម៉ែ
ឪវានឹងណាស់កាលពីមុននឹងវាធ្វើការងារនៅធនាគារអេស៊ីលីដា រួចទៅវាស៊ីឈ្មោះគេ
មានឈ្មោះទាហ៊ានមួយ មានឈ្មោះអេស៊ីលីដាមួយដែរ

ក៖  អូ៎!មានឈ្មោះពីរហោសអ៊ុំ?

ខ៖  នឹងហើយដល់ពេលដែរធ្វើយូរៗទៅគេដឹងហាសគេអោយយើងឈប់មួយនឹង
ដល់ពេលងោយឈប់ មួយចឹងទៅក៏សំរេចងោយវាឈប់ការងារឯកជនទៅ
អោយវាធ្វើការងាររដ្ឋទៅណាស់

ក៖  អូ៎!ចឹងគាត់ធ្វើជាទាហ៊ានទៅ?

ខ៖  នឹងបានធ្វើជាទាហ៊ាននៅភ្នំពេញនឹងអានឹងស្អីក៏អត់គ្រឿងញៀនក៏អត់ដែរនឹង
គ្រាន់តែវាផឹកបន្តិចនឹងណាស់

ក៖  អូ៎!គាត់ផឹកច្រើនណាអ៊ុំ?

ខ៖  មិនមែនច្រើនប៉ុន្មានទេប៉ុន្តែដូចថាអត់ចូលចិត្តនឹងពីព្រោះក្មេងខ្លាចវាខូចខួរក្បាលនឹង
អាជៀសវៀងមើលទូរស័ព្ទនឹងក៏មិនចង់អោយមើលដែរនឹង

ក៖  មើលទូរស័ព្ទច្រើនខូចភ្នែកហោសអ៊ុំ?

ខ៖  នឹងហើយអាចធ្វើអោយខូចភ្នែកនឹង ខូចខួរក្បាលនឹង

កៈ
ប៉ុន្តែដោយសារតែសម័យឥឡូវនឹងជាសម័យប្រព័ន្ធអ៊ីនធ័រណេតដល់ពេលចឹងវាពិបាកហាមក្មេងចឹង ហាសអ៊ុំ?

ខៈ ចា៎!នឹងហើយ

កៈ ចឹងមានអីដែរអ៊ុំចង់ផ្ដែផ្ដាំអីផ្សេងទៀតទេអ៊ុំ?

ខៈ គ្មានស្អីទេគ្រាន់តែថាអោយបងប្អូនខ្មែរទាំងអស់នឹងចេះស្រលាញ់ខ្មែរនឹង
កុំយកបរទេសនឹងមកធ្វើជា ខែលអីចឹងកុំអោយយើងដើរតាមគេចឹងទៅ
ពេលដែរខ្វះខាតគិតថាគ្មាននរណាគេជួយជាងគ្នាយើងទេនឹង

កៈ
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដូចជាបានផ្ដល់ពេលវេលាដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិ
របស់អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាណាស់អ៊ុំ?

ខៈ ចា៎!នឹងហើយ

កៈ បាទចឹងអរគុណច្រើនអ៊ុំ៕៕៕